# ការអនុវត្តន៍ល្អ
## ការរៀបចំប៉ុស្តិ៍ការងារនៅផ្នែកពិនិត្យគុណភាព

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ដោយសារការពិនិត្យគុណភាពមានសារៈសំខាន់នៅក្នុងផលិតកម្មវាយនភ័ណ្ឌ ដូចនេះត្រូវរៀបចំប៉ុស្តិ៍ការងារផ្នែកពិនិត្យគុណភាពអោយបានល្អប្រសើរ ។ ការរៀបចំប៉ុស្តិ៍ការងារមិនបានល្អអាចធ្វើអោយគុណភាពការងារចុះខ្សោយ និងធ្វើអោយខូចឈ្មោះរោងចក្រ ។ នៅពេលរៀបចំប៉ុស្តិ៍ការងារ ត្រូវផ្តល់ពន្លឺអោយបានគ្រប់គ្រាន់ ណែនាំការងារអោយច្បាស់ និងផ្តល់គ្រប់ឧបករណ៍ដែលចាំបាច់ដល់កម្មករ ។

### *ការអនុវត្តន៍ល្អក្នុងការរៀបចំតុពិនិត្យគុណភាព*

ធានាការផ្តល់ពន្លឺអោយបានច្បាស់ ប៉ុន្តែពន្លឺដាច់ខាតមិនត្រូវជះចំភ្នែកកម្មករឡើយ (រូបភាពទី១) ។

ផ្តល់ការណែនាំការងារអោយបានច្បាស់លាស់ជាភាសា ដែលកម្មករអាចយល់ ដោយមានបង្ហាញជា រូបភាពផងបើចាំបាច់ (រូបភាពទី២) ។

ម៉ែត្ររង្វាស់ត្រូវបិតភ្ជាប់នឹងតុការងារ ដើម្បីជាជំនួយដល់កម្មករនៅពេលពិនិត្យខ្នាតសំលៀកបំពាក់ ។ រង្វាស់ម៉ែត្រនេះ ត្រូវបិតជាប់ជាអចិន្ត្រៃយ៍ដើម្បីបង្ហាញពីខ្នាតផ្សេងៗរបស់សំលៀកបំពាក់ ដែលត្រូវពិនិត្យ (រូបភាពទី៣) ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ បង្កើនគុណភាព និងផលិតភាព
- ✓ កាត់បន្ថយភាពនឿយណាយ និងកំហុសការងាររបស់កម្មករ
- ✓ ពិនិត្យគុណភាពកាន់តែមានភាពងាយស្រួល ជាពិសេសទៅទៀតនៅពេលពិនិត្យផលិតផលថ្មី
- ✓ ធានាថាកម្មករ ត្រូវបានណែនាំច្បាស់លាស់ពីការងារ ដើម្បីអោយកម្មករបានយល់ពីអ្វីដែលជាតំរូវការចាំបាច់របស់គុណភាព

### តាមរបៀបណា:

- ✓ បុគ្គលិករោងចក្រ ត្រូវបង្កើតប៉ុស្តិ៍ការងារពិនិត្យគុណភាពដោយប្រើប្រាស់បន្ទះក្តារពណ៌សលាត
- ✓ បំពាក់ពន្លឺអោយបានគ្រប់គ្រាន់
- ✓ បិទរង្វាស់ម៉ែត្រលើតុការងារនីមួយៗ
- ✓ ផ្តល់ការណែនាំពីការពិនិត្យគុណភាពដល់កម្មករតាមរយៈការសរសេរ និងរូបភាព

### តំលៃ:

**$**

- $ តំលៃទាប
- $$ តំលៃមធ្យម
- $$$ តំលៃខ្ពស់

អង្គការ
ពលកម្ម
អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉ែល betterfactories@ilo.org